# សន្តី ថេរេសា

## នៃព្រះកុមារយេស៊ូ



# សន្តី ថេរេសា
# នៃព្រះកុមារយេស៊ូ

រៀបរៀង និងកែសម្រួលដោយ
លោកបូជាចារ្យ **ហ្វ្រង់ស្វ័រ អេមេល្យដាល**

នេះគឺ **ម៉ារី ប៉ូលីន ឡេអូនី** និង **សេលីន** ដែលជាកូនស្រីរបស់លោក និងអ្នកស្រី **ម៉ារតាំង**។ ពួកនាងកំពុងតែសប្បាយរីករាយជុំវិញអង្រឹងរបស់ប្អូនស្រីតូចដែលទើបនឹងកើតក្នុងថ្ងៃទី២ ខែមករា ឆ្នាំ ១៨៧៣ នៅ អាឡង់សុង ហើយគេដាក់ឈ្មោះឲ្យទារិកានេះថា **ថេរេសា**។

ថេរេសា ជាកូនង៉ែតដូចកូនង៉ែតឯទៀតៗដែរ ប៉ុន្តែថ្ងៃមួយនោះ សកលលោកទាំងមូលបានស្គាល់ និងស្រឡាញ់នាងតូច "ថេរេសា" នេះយ៉ាងខ្លាំង នាងតូចនេះ គឺជា សន្តី ថេរេសា នៃព្រះកុមារយេស៊ូ និងព្រះភក្ត្រាដ៏វិសុទ្ធ។



**ថេរេសា** ចម្រើនវ័យក្នុងក្រុមគ្រួសារដែលស្រឡាញ់ និងថ្នាក់ថ្នមនាងខ្លាំងណាស់។ ឪពុករបស់នាង ហៅនាងថា "ម្ចាស់ក្សត្រីតូចរបស់ពុក"។





ក្មេងស្រីតូចនេះ មិនសូវជាស្លូតប៉ុន្មានទេ ប៉ុន្តែ នាងខិតខំប្រែអាកប្បកិរិយារបស់នាងបន្តិចម្តងៗ ដើម្បីផ្គាប់ព្រះហឫទ័យព្រះយេស៊ូ។



**ថេរេសា** ចូលចិត្តអធិដ្ឋាន និងទូលទៅព្រះយេស៊ូថា នាងស្រឡាញ់ព្រះអង្គខ្លាំងណាស់ និងអរព្រះគុណព្រះអង្គ ដែលបានប្រទានភាពរីករាយដល់នាង ហើយនាងក៏តែងតែយកទុក្ខព្រួយទាំងប៉ុន្មានរបស់ខ្លួនទូលថ្វាយទៅព្រះអង្គវិញដែរ។

ពេលនាងមានអាយុបួនឆ្នាំ ទុក្ខសោកមួយយ៉ាងធំ
បានមកគ្របដណ្ដប់លើក្រុមគ្រួសារនាង  គឺម្ដាយ
របស់នាងមានជំងឺជាទម្ងន់ ហើយបាត់បង់ជីវិតទៅ។
បន្ទាប់មក មានតែបងស្រី **ម៉ូលីន** ទេដែលជាអ្នក
មើលថែនាង ហើយនាងហៅគាត់ថា "ម៉ាក់តូច!"។



ខែវិច្ឆិកា ឆ្នាំ១៨៧៧ លោក **ម៉ាវតាំខ** និងកូន ស្រីទាំងអស់ បានចាកចេញពីអាឡុងសុងទៅរស់នៅឯលីស៊ីឃើស ក្នុងគេហដ្ឋានធំទូលាយមួយ ដែលគេដាក់ឈ្មោះថា "ព្រៃគុម្ពោត"។ នៅទីនោះ **ថេរេសា** ឧស្សាហ៍ទៅលេងនឹងឪពុកមា និងម្តាយមីង និងបងស្រីជីដូនមួយរបស់ខ្លួនពីរនាក់ទៀតដែរ។





ជូនកាលឪពុករបស់នាងនាំនាងទៅស្ទួចត្រី។ ក្មេងស្រីតូចនេះចូលចិត្តគយគន់ធម្មជាតិណាស់ ទាំងនឹកកោតសរសើរក្នុងចិត្តថា៖ ព្រះជាម្ចាស់ប្រទានអ្វីៗគ្រប់បែបយ៉ាងមកមនុស្សយើង ពីព្រោះព្រះអង្គស្រឡាញ់មនុស្សយើង។



ថ្ងៃមួយ **ម៉ូលីន** សម្រេចចិត្តថា ទៅបួសជាដូនជីនៅអារាមការមែល នៅ លីស៊ីយើស។ ស្រីតូច **ថេរេសា** កើតទុក្ខក្រៀមក្រំយ៉ាងខ្លាំង ក្រោយពីបានដឹងរឿងនេះ ហើយនាងធ្លាក់ខ្លួនឈឺជាទម្ងន់។ ប៉ុន្តែនាងមានអារម្មណ៍ធូរស្រាល និងជាសះស្បើយភ្លាម ក្រោយពីបានមើលឃើញរូបចម្លាក់របស់ព្រះនាងព្រហ្មចារិនីម៉ារីដ៏វិសុទ្ធដែលតាំងនៅក្បែរគ្រែរបស់នាង ញញឹមដាក់នាង។



ថ្ងៃទី៨ ខែឧសភា ឆ្នាំ១៨៨៤ ជាថ្ងៃប្រកបដោយ
សុភមង្គលសម្រាប់ **ថេរេសា** ព្រោះនាងបានទទួល
ព្រះកាយព្រះគ្រីស្តជាលើកដំបូង។ នាងហៅថ្ងៃនោះ
ថា ជា "ថ្ងៃដំបូងដែលព្រះកាយថើបព្រលឹងខ្ញុំ"។



បន្ទាប់ពី **ប៉ូលីន** គឺ **ម៉ារី** ដែលបានចូលទៅរស់នៅក្នុងអារាមការមែល។ ឥឡូវនេះ ថេរេសា ក៏ចង់ក្លាយទៅជាដូនជីទៀតដែរ។ ឪពុករបស់នាងយល់ព្រមជានិច្ច ទោះបីពេលនោះ គាត់កើតទុក្ខយ៉ាងខ្លាំងក៏ដោយ។



ប៉ុន្តែ ការអនុញ្ញាតរបស់ឪពុកនាងមិនគ្រប់គ្រាន់ឲ្យនាងទៅជាដូនជីបានទេ ដោយហេតុថា **ថេរេសា** នៅក្មេងពេក នាងមានអាយុទើបតែដប់ប្រាំឆ្នាំប៉ុណ្ណោះ ហើយលោកអភិបាលព្រះសហគមន៍ក៏មិនយល់ព្រមដែរ។ លោក **ម៉ារតាំង** នាំ **សេលីន** និង ថេរេសា ទៅធ្វើបូជនីយេសចរណ៍នៅទីក្រុងរ៉ូម។



នៅវ៉ាទីកង់ **ថេរេសា** ហ៊ានចូលទៅសូមការអនុញ្ញាត ពីសម្ដេច ប៉ាប ដើម្បីបានសិទ្ធិចូលរស់នៅក្នុងអារាម ការមែល ក្នុងអាយុដប់ប្រាំឆ្នាំ។ សម្ដេច ប៉ាប គ្រាន់ តែឆ្លើយតបទៅនាងថា៖ "បើជាព្រះបំណងរបស់ ព្រះជាម្ចាស់ នាងមុខជានឹងបានចូលមិនខាន"។



ពេលត្រឡប់មកដល់លីស៊ីយើសវិញ **ថេរេសា** បាន ទទួលសំបុត្រមួយអំពីលោកអភិបាលព្រះសហគមន៍ ដែលយល់ព្រមឲ្យនាងទៅរស់នៅក្នុងអារាមការមែល ទោះបីនាងមានអាយុតិចក៏ដោយ។



ថ្ងៃទី៩ ខែមេសា ឆ្នាំ១៨៨៨ **ថេរេសា** បាន សម្រេចបំណងរបស់នាងហើយ។ ទីបំផុត ទ្វារអារាមការមែល បើកចំហទទួលនាង ហើយបន្តិចទៀត នាងនឹងថ្វាយខ្លួនទាំងស្រុងចំពោះព្រះយេស៊ូ។





ឥឡូវនេះនាងស្លៀកពាក់ជាអ្នកត្រៀមខ្លួន មានន័យថា ជាយុវនារីដែលចាប់ផ្ដើមជីវិតជាអ្នកបួសហើយ។ ក្នុងមួយថ្ងៃៗ នាងត្រូវចំណាយពេលវេលាដើម្បីរៀនសូត្រ អធិដ្ឋាន និងបំពេញការងារតូចតាចប្រចាំថ្ងៃដូចបងស្រីឯទៀតៗដែរ។

នាងបានទទួលការអនុញ្ញាតឲ្យចូលទៅរស់នៅទីនោះ ក្នុងករណីពិសេស។ វិន័យនៅទីនោះតឹងរឹងចំពោះនាង ដើម្បីកុំឲ្យនាងមានអំនួត។ មានបងស្រីខ្លះ ស្តីបន្ទោសនាងយ៉ាងខ្លាំងទៀតផង។ ដោយសារសេចក្តីស្រឡាញ់ចំពោះព្រះយេស៊ូ នាងទ្រាំទ្រទទួលការលំបាកសព្វបែបយ៉ាង ជាមួយនឹងស្នាមញញឹមជានិច្ច។



ថ្ងៃទី១០ ខែមករា ឆ្នាំ១៨៨៩ ទោះបីជាមានសុខភាពមិនល្អក៏ដោយ ក៏ឪពុករបស់ **ថេរេសា** ខិតខំអញ្ជើញមកចូលរួមក្នុងពិធីដ៏រំភើបចិត្តមួយ គឺ "ម្ចាស់ក្សត្រីតូចរបស់គាត់" ទទួលសម្លៀកបំពាក់ជាអ្នកបួស។ ចាប់ពីថ្ងៃនោះ នាង **ថេរេសា** បានស្លៀកពាក់តាមរបៀបជាដូនជីនៅអារាមការមែលរហូតមក។





ពេលនោះ នៅខាងក្រៅមានព្រិលគ្របដណ្តប់ពាស ពេញលើអ្វីៗទាំងអស់។ **ថេរេសា** សប្បាយចិត្ត ណាស់ នាងគិតថា ធម្មជាតិទាំងឡាយ ដែល គ្របដណ្តប់ដោយព្រិលពណ៌ស គឺហាក់បីដូចជា រូបនាងដែលបានគ្របដណ្តប់ដោយសម្លៀកបំពាក់ ពណ៌សដែរ។ ចាប់ពីពេលនេះទៅ នាងមានឈ្មោះ ថា "ប្អូនស្រីថេរេសានៃព្រះកុមារយេស៊ូ"។



នៅថ្ងៃទី៨ ខែកញ្ញា ឆ្នាំ១៨៩០ **ថេរេសា** បាន ថ្វាយពាក្យសច្ចាគឺ មួយជីវិតនេះនាងថ្វាយខ្លួនទាំង ស្រុង ចំពោះព្រះយេស៊ូជាអម្ចាស់។ ស្បៃគ្របមុខ ពណ៌សរបស់នាង ត្រូវជំនួសដោយស្បៃខ្មៅវិញ។





នាងដឹងថា ដើម្បីស្រឡាញ់ព្រះយេស៊ូដ៏ពិតប្រាកដនោះ ត្រូវតែស្រឡាញ់អ្នកដែលរស់នៅជាមួយនាង។ ហេតុនេះហើយ ទើបនាងខិតខំធ្វើខ្លួនឲ្យគេស្រឡាញ់ និងជួយយកអាសារដូនជីឯទៀតៗ ជាពិសេសដូនជីដែលមិនចូលចិត្តនាង។



**ថេរេសា** មានអំណោយទានខាងសិល្បៈ។ នាងគូររូបសន្តបុគ្គលទាំងឡាយ ដែលគេគោរព ឬ តុបតែងលម្អវត្ថុនានា សម្រាប់សាសនា។ នាងសរសេរកំណាព្យ និងរឿងល្ខោន ហើយដើរតួដោយខ្លួននាង ជាមួយនឹងបងស្រីឯទៀតៗ។

ថ្ងៃខែឆ្នាំចេះតែកន្លងផុតទៅ។ គេប្រគល់ការងារឲ្យបងស្រី **ថេរេសា** បង្រៀនប្អូនស្រីឯទៀតៗដែលត្រៀមខ្លួនចូលបួស ឲ្យចេះប្រកាន់ឥរិយាបថរស់នៅជាបុត្រធីតារបស់ព្រះបិតា ដែលពោរពេញទៅដោយព្រះហឫទ័យប្រណីសន្តោសចំពោះខ្លួន។





ពេលនេះ **ថេរេសា** ធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរណាស់។ នាងចេះតែអស់កម្លាំង ខ្សោយទៅៗ ហើយក្អកជាញឹកញាប់ផង។ អ្នកទទួលខុសត្រូវ គឺដូនជី **អាញ៉េស** ដែលជាបងស្រី **ម៉ូលីន** បានណែនាំឲ្យនាងសរសេររៀបរាប់អំពីខ្សែជីវិតរបស់នាងជាលាយលក្ខណ៍អក្សរ។ រឿងនិទាននេះ បានក្លាយទៅជាសៀវភៅមួយដែលមានចំណងជើងថា "ប្រវត្តិនៃព្រលឹងមួយ"។

**ថេរេសា** ចុះខ្សោយកម្លាំងដើរស្ទើរតែពុំរួច។ ប៉ុន្តែ នាងខិតខំដើរពីរបីជំហាន ដោយកំណត់ក្នុងចិត្តថា "ខ្ញុំដើរដើម្បីសាសនទូតម្នាក់"។ តាមពិតទៅ នាងបានសរសេរសំបុត្រជារឿយៗផ្ញើជូនទៅសាសនទូតពីររូប ដើម្បីគាំទ្រពួកគេ ហើយនាងក៏អធិដ្ឋាន និងថ្វាយសក្ការបូជាចំពោះព្រះយេស៊ូ ដោយសូមឲ្យព្រះអង្គជួយគាំទ្រពួកគេផង។







នៅខែកក្កដា ឆ្នាំ១៨៩៧ គេនាំ **ថេរេសា** ទៅសម្រាកព្យាបាលនៅក្នុងគិលានដ្ឋាន ប្រចាំអារាម។ នាងដឹងថា ជីវិតដល់ថ្ងៃបញ្ចប់ហើយ នាងនិយាយថា "ខ្ញុំមិនស្លាប់ទេ តែខ្ញុំដើរចូលទៅក្នុងជីវិតវិញ"។

ថ្ងៃទី៣០ ខែកញ្ញា សភាពជំងឺរបស់នាងកាន់តែដុនដាបទៅៗ។ ដោយសម្លឹងមើលទៅព្រះឈើឆ្កាងរបស់នាង ពេលនោះ នាងស្រែកឡើងថា៖ "ខ្ញុំស្រឡាញ់ព្រះអង្គ! ឱព្រះជាម្ចាស់អើយ ខ្ញុំស្រឡាញ់ព្រះអង្គ!"។ នោះគឺជាសម្ដីចុងក្រោយបំផុតរបស់បងស្រី ថេរេសា...។

អនុញ្ញាតឲ្យបោះពុម្ពដោយ

លោក **អូលីវីយេ ឝ្មិតហាស្លេរ** (MEP)

អភិបាលព្រះសហគមន៍កាតូលិក ភូមិភាគភ្នំពេញ

ឆ្នាំ ២០១៣

Imprimatur by Bishop

**OLIVIER SCHMITTHAEUSLER**, MEP

APOSTOLIC VICAR OF PHNOM PENH

CAMBODIA 2013

ISBN 978-99963-13-44-8

បោះពុម្ពនៅភ្នំពេញ ឆ្នាំ ២០១៣

©មណ្ឌលអប់រំជំនឿកាតូលិកកម្ពុជា (CCCC)

ផ្ទះលេខ ៥៧ ផ្លូវលេខ ១០១ សង្កាត់បឹងត្របែក រាជធានីភ្នំពេញ, E-mail : 4c@online.com.kh